# ឯកសារជំនួយស្មារតី
## របស់ ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្ត
## ស្តីពី
## “ភាពជោគជ័យរយៈពេល ០៥ឆ្នាំ របស់រដ្ឋបាលខេត្តមណ្ឌលគិរី”
## ក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការគណៈរដ្ឋមន្ត្រី
(ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣)

## អ រ គុ ណ ស ន្តិ ភា ព !

**ជាបឋម ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ**

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ !
- សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម **សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !
- សូមក្រាបបង្គំទូលថ្វាយ សម្តេចព្រះមហាក្សត្រី នរោត្តម **មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
- សូមគោរព សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភាជាតិ និង **លោកជំទាវ** ជាទី គោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាជាតិ និង សម្តេចធម្មវិសុទ្ធវង្សា **សៅ ធី ហេង សំរិន** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង **លោកជំទាវ** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ព្រមទាំងសហការី ***ជាទីគោរពដ៏ខ្ពង់ខ្ពស់ !***
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បងប្អូនអ្នកសារព័ត៌មានជាតិ អន្តរជាតិ ព្រមទាំង សមាជិក សមាជិក ទាំងអស់ ដែលមានវត្តមាននៅក្នុងអង្គសន្និសីទសារព័ត៌ មាន នាពេលនេះ ***ជាទីមេត្រី !***
- បងប្អូនប្រជាពលរដ្ឋ និងជនរួមជាតិ ដែលបាន និងកំពុងតាមដានទស្សនាការផ្សាយផ្ទាល់

សន្និសីទ សារព័ត៌មានស្តីពីវឌ្ឍនភាព និងទិសដៅការងារអនុវត្តបន្ត របស់រដ្ឋបាលខេត្តមណ្ឌលគិរី នាឱកាសដ៏មានសារសំខាន់នាពេលនេះ ***ជាទីគោរពស្រលាញ់រាប់អាន !***

ជាបឋម ជំនួសមុខឱ្យក្រុមប្រឹក្សា គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋខេត្តមណ្ឌលគិរី និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំបាទមានបេតិសោមនស្សរីករាយ យ៉ាងក្រៃលែង និងមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយបានចូលរួមនៅក្នុងសន្និសីទសារព័ត៌មាន ដែលបានរៀបចំឡើងដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល និងសូមគោរពថ្លៃងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មានស្តីពី "**ភាពជោគជ័យក្នុងរយៈពេល ០៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តមណ្ឌលគិរី**" នេះឡើង និងបានផ្តល់ឱកាសឱ្យខ្ញុំបាទបានចូលរួមជាវាគ្មិន ដើម្បីបង្ហាញជូនសាធារណជនឱ្យបានយល់ជ្រួតជ្រាបអំពីវឌ្ឍនភាព ការអភិវឌ្ឍរីកចម្រើន និងទិសដៅការងារបន្តរបស់ខេត្តមណ្ឌលគិរី ក្រោមការដឹកនាំប្រកប ដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ និងឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ ទន្ទឹមនឹងនោះដែរ សូមអរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គសន្និសីទដ៏មានសារសំខាន់ នាពេលនេះ ។

ក្នុងនាមក្រុមប្រឹក្សា គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទាំងអស់នៅក្នុងខេត្តមណ្ឌលគិរី ខ្ញុំសូមយកឱកាសនេះ សម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែង និងយកជីវិតធ្វើជាដើមទុនក្នុងការនាំយកមកវិញនូវ សុខសន្តិភាពជូនប្រទេសជាតិ និងពលរដ្ឋកម្ពុជា "**សូមអរគុណសន្តិភាព**" ដែលធ្វើឲ្យប្រទេសជាតិមាន ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសរក្សាបាននូវកំណើតសេដ្ឋកិច្ច ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋទូទាំងប្រទេសបានជាបន្តបន្ទាប់។ តាមរយៈការដាក់ចេញនូវគោលនយោបាយឈ្នះឈ្នះ របស់សម្តេចតេជោ បានធ្វើឱ្យប្រទេសជាតិ វិត្រឡប់មករកសន្តិភាពពេញបរិបូណ៌ ធ្វើឱ្យប្រជាពលរដ្ឋទូទាំងប្រទេសទទួលបាននូវ សិទ្ធិសេរីភាព និងការរស់រានប្រកបមុខរបរចិញ្ចឹមជីវិតដោយពុំមានការភ័យខ្លាច។ កត្តាខាងលើនេះបានជម្រុញការអភិវឌ្ឍ លើគ្រប់វិស័យ ទាំងពេលបច្ចុប្បន្ន និងទៅអនាគត ។

ដោយអនុវត្តតាមគោលនយោបាយដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងមានកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ ជាគោល និងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ផែនការវិនិយោគ៣ឆ្នាំរំកិល ដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្ត សម្រាប់ជាត្រីវិស័យ ក្នុងការអនុវត្តការងារនៅក្នុងរយៈពេល ០៥ឆ្នាំនេះ រដ្ឋបាលខេត្តមណ្ឌលគិរី បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អនុវត្តការងារ និងសម្រេចបាននូវសមិទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម ៖

## I-អំពីស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រខេត្តមណ្ឌលគិរី

ខេត្តមណ្ឌលគិរី ស្ថិតនៅភូមិភាគឥសាន្ត នៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ **៣៨២ គីឡូ ម៉ែត្រ** ពីរាជធានីភ្នំពេញ ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ប្រជុំភ្នំ ខ្ពង់រាប សំបូរដោយជ្រោះជ្រង ជ្រលងជងអូ រតិរីបព្វតាជាច្រើន និងជាខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម មានព្រំប្រទល់ ៖

- ខាងលិចទល់នឹង ខេត្តក្រចេះ
- ខាងជើងទល់នឹង ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី
- ខាងកើត និងខាងត្បូងទល់នឹង ខេត្តដាក់ឡាក់ ខេត្តដាក់ណុង និងខេត្តប៊ិញភឿក នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រវែង **៣១៤.៦៦៤ គីឡូម៉ែត្រ** ។
- ផ្ទៃដីខេត្តសរុប មានទំហំ **១៤ ២៨៨ គ.ម²** ។
- មាន ក្រុង១ និងស្រុក៤ ឃុំ១៧ សង្កាត់ចំនួន ០៤ និងភូមិចំនួន ៩២ ។
- ប្រជាពលរដ្ឋសរុប **៩៧ ៥៦២នាក់ ស្រី ៤៧ ៥៨៣នាក់ ស្មើនឹង ២៣ ៥៤០គ្រួសារ** អ្នកដែលមានអាយុ ១៨ឆ្នាំឡើងមានចំនួន **៤៩ ៧០៩ នាក់** ដង់ស៊ីតេ **៧ នាក់ ក្នុង ១គីឡូម៉ែត្រ** ។
- ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចនៅទូទាំងខេត្តមានចំនួន **៥៣ ៤៤៤ នាក់** ស្មើនឹង **៥៥%** នៃប្រជាជនសរុប មានចំនួន ០៨ជនជាតិ ក្នុងនោះរួមមាន ព្នង ក្រោល គ្រឹង ស្ទៀង ទំពួន ចារាយ ថ្មូន និងកួយ ។
- ប្រជាពលរដ្ឋប្រកបមុខរបរចម្បងក្នុងវិស័យកសិកម្មមាន **៨២%** វិស័យសិប្បកម្ម **១%** និងវិស័យសេវាកម្ម **១៧%** ។
- ខេត្តមណ្ឌលគិរី មានច្រកទ្វារព្រំដែនទ្វេភាគីសំខាន់ៗចំនួន ០៣ សម្រាប់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយប្រទេសវៀតណាម ក្នុងនោះមាន ៖ ច្រកទ្វារទ្វេភាគីឡាប៉ាខេ ស្ថិតក្នុងស្រុកកែវសីមា, ច្រកទ្វារទ្វេភាគីដាក់ដាំ ក្នុងស្រុកអូររាំង និងច្រកទ្វារទ្វេភាគីណាំលៀរ ក្នុងស្រុកពេជ្រាដា។ ដោយឡែកច្រកទ្វារដីមៀត ស្រុកកោះញែក មិនទាន់ដំណើរការ។
- សេដ្ឋកិច្ចខេត្តមណ្ឌលគិរីមានចំនួនសរុបប្រមាណ ១៦៤ លានដុល្លារ ស្មើនឹង ១.៣% នៃសេដ្ឋកិច្ចជាតិ។ សេដ្ឋកិច្ចខេត្តមានកំណើន ១.៤% នៅឆ្នាំ២០២១។ ប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ មានចំនួន ១ ៦៨៧ ដុល្លារ (នៅឆ្នាំ២០២១ ប្រាក់ចំណូលនេះរងផលប៉ះពាល់ដោយសារកូវីដ-១៩។
- តាមរយៈកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលបានផ្ទេរមុខងារ និងធនធាន ព្រមទាំងបានធ្វើប្រតិភូកម្មជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យកាន់តែមានលទ្ធភាព និងសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈ និងសេវាចាំបាច់នានាជូនប្រជាពលរដ្ឋ ព្រមទាំងអាចដោះស្រាយបញ្ហាប្រឈម នៅមូលដ្ឋានបានឆាប់រហ័យ និងទាន់ពេលវេលា។

❖ ការងារផ្តល់សេវាតាមច្រកចេញ-ចូលតែមួយរដ្ឋបាលខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលក្រុង ស្រុកបានដើរតួនាទីយ៉ាងសំខាន់ក្នុងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការផ្តល់សេវាពាក់ព័ន្ធនឹងវិស័យសំខាន់ៗចំនួន ១៤ វិស័យ និងបានផ្តល់សេវាសរុបមានចំនួន ១២,៧២៦ សេវា មានទឹកប្រាក់សរុបចំនួន ២,៤៦១,៨៣៧,៤៨៨រៀល (ពីរបីលាន បួនរយហុកសិបមួយលាន ប្រាំបីរយសាមសិបប្រាំពីពាន់ បួនរយប៉ែតសិបប្រាំបីរៀល) ។

❖ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត តាមរយៈការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព បានទប់ស្កាត់ បង្រ្កាបបទល្មើសផ្សេងៗ ពិសេសការទប់ស្កាត់សកម្មភាពចែកចាយគ្រឿងញៀន និងការជួញដូរមនុស្ស ដោយធានាបានសន្តិសុខ របៀបរៀបរយល្អនៅថ្នាក់មូលដ្ឋាន ឆ្លើយតបទាន់ពេលវេលា និងឆាប់រហ័យប្រកបដោយប្រសិទ្ធិភាព។ រក្សាបាននូវស្ថិរភាពសន្តិសុខ សណ្តាប់ធ្នាប់ផ្ទៃក្នុងខេត្ត និងនៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា-វៀតណាម មិនមានអ្វីកើតឡើងគួរឱ្យកត់សម្គាល់ ។

## II.អំពីសក្តានុពល និងសមិទ្ធផលសំខាន់ៗ តាមវិស័យដែលខេត្តសម្រេចបាន៖

➢ **វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ៖** ខេត្តមណ្ឌលគិរីមានផ្ទៃដីធំទូលាយ ប្រកបដោយដីរដាតិ អំណោយផលខ្ពស់ក្នុងការដាំដុះដំណាំកសិកម្ម និងដំណាំកសិ-ឧស្សាហកម្ម អនុវត្តបាន៖

❖-ការងារដាំដុះដំណាំកសិកម្ម ក្នុងនោះ ដំណាំស្រូវរហូតមកដល់ឆ្នាំ២០២២ នេះ អនុវត្តបានលើផ្ទៃដីទំហំ ២៩,៣៦៤ ហិកតា មានការកើនឡើងធៀបនឹងឆ្នាំមុនៗ

❖ ដំណាំសាកវប្បកម្ម៖ (ដំណាំបន្លែ ដំណាំហូបផ្លែ ដំណាំរួមផ្សំ) ផ្ទៃដីដាំដុះដំណាំសរុប ២,០៨៣ ហិកតា ដំណាំឧស្សាហកម្មផ្ទៃដីដាំដុះសរុប ១៥,៤៤៩ ហិកតា (ប័រ ផាស៊ីន កាហ្វេ កាកាវ....ល)។

❖បច្ចុប្បន្ន ខេត្តមណ្ឌលគិរីមានក្រុមហ៊ុនសរុបចំនួន **២៥ ក្រុមហ៊ុន** ដែលកំពុងធ្វើការវិនិយោគលើផ្ទៃដី **១៤៧.០១៣,០៥ហិកតា** ។

❖ ដំណាំកៅស៊ូនៅទូទាំងខេត្តសរុបចំនួន **៤២.៥៣៧,៤១ ហិកតា** ក្នុងនោះ **កៅស៊ូក្រុមហ៊ុន** មានផ្ទៃដីដាំដុះចំនួន ៣១.២៣១,៩៨ ហិកតា ទទួលបានបរិមាណផលជ័រស្ងួត ៦,០១៧.៣៩តោន និង

❖ **កៅស៊ូគ្រួសារ** បានដាំដុះលើផ្ទៃដីសរុបចំនួន ១១,៥៧០.៤៣ ហិកតា ស្មើនឹង ១,៥៩៤ គ្រួសារ ទទួលបានទិន្នផលជ័រកៅស៊ូស្ងួតសរុប ១០,០៦៣,១ តោន

➢ **វិស័យទេសចរណ៍៖** មានតំបន់រមណីយដ្ឋានទេសចរណ៍វប្បធម៌ និងធម្មជាតិក្នុងខេត្តសរុប ចំនួន ១០៥ កន្លែង ក្នុងនោះ រមណីយ៍ដ្ឋានមានសេវាកម្មស្នាក់នៅ និងរមណីយ៍ដ្ឋានគ្មានសេវាកម្មស្នាក់នៅ ចំនួន ៣៨ កន្លែង ស្មើនឹង ៥៥៦ បន្ទប់ ។

❖ សណ្ឋាគារ ០៦ កន្លែង ស្មើនឹង ២៥៧ បន្ទប់, ផ្ទះសំណាក់ ៣៦ កន្លែង ស្មើនឹង ៥៣៥ បន្ទប់, ម៉ូតែល និង ប៊ូទិក ១០ កន្លែង ស្មើនឹង ២១៩ បន្ទប់។

❖ ភោជនីយដ្ឋាន និង អាហារដ្ឋានមាន ៣០ កន្លែង, ខារ៉ាអូខេ ១២ កន្លែង ស្មើនឹង ៥៦ បន្ទប់, ម៉ាស្សា ០៤ កន្លែង ។

❖ មគ្គុទេសក៍ទេសចរណ៍មាន ចំនួន ៧៥ នាក់ ស្រី ០៥ នាក់ និង មានក្រុមហ៊ុនវិនិយោគលើវិស័យទេសចរណ៍ចំនួន ០៣ ក្រុមហ៊ុន ។ ស្ថានភាពភ្ញៀវទេសចរណ៍រួមមាន៖

-ឆ្នាំ២០១៨ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ កើនឡើង ១៧.៩៣%

-ឆ្នាំ២០១៩ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ កើនឡើង ២០.៣៩%

-ឆ្នាំ២០២០ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ កើនឡើង ៤.៦១%

-ឆ្នាំ២០២១ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ ថយចុះ ០.៥២%

-ឆ្នាំ២០២២ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ កើនឡើង ២១.៨២%

➢ **វិស័យគមនាគមន៍ ៖** ផ្លូវគមនាគមន៍ក្នុងខេត្តមានប្រវែងសរុប **៨៥១,៣៧៦ គ.ម** ក្នុងនោះផ្លូវក្នុងខេត្តចំនួន **០៨ ខ្សែ** ប្រវែង **៥៣០,៥ គ.ម** ផ្លូវក្នុងក្រុងចំនួន **៥៩ ខ្សែ** ប្រវែង **៦៥.៨៧៦ ម** និង ផ្លូវលំចំនួន ៣២ ខ្សែ ប្រវែង **២៥៥ គ.ម** ។

❖ ផ្លូវជាតិលេខ៧៦ ពីស្រុកស្នួល ខេត្តក្រចេះ មកក្រុងសែនមនោរម្យមានប្រវែង **១២៧ គ.ម** និងពីក្រុងសែនមនោរម្យ ទៅតាអង្គ ស្រុកកូនមុំ ខេត្តរតនគិរី មានប្រវែង **១៧២ គ.ម** ។

❖ ផ្លូវលេខ៧៥ ផ្លូវលំពីស្រុកកោះញែក ទៅស្រុកចិត្របុរី ខេត្តក្រចេះ មានប្រវែង **១៥០ គ.ម**

❖ ផ្លូវច្រកទ្វារព្រំដែនទ្វេភាគី តភ្ជាប់តំបន់ព្រំដែនជាមួយវៀតណាម មានចំនួន ០៣ ខ្សែ ប្រវែង **៨៧ គ.ម** ។

➢ **វិស័យធនធានរ៉ែ និង ថាមពល៖**

ខេត្តមណ្ឌលគិរី មានធនធានរ៉ែជាច្រើនប្រភេទ ដូចជា រ៉ែមាស បុកស៊ីត សំណរ និងរ៉ែលោហធាតុផ្សេងទៀត។ ក្រុមហ៊ុនដែលទទួលបានសិទ្ធិក្នុងការសិក្សា និងវិនិយោគវិស័យធនធានរ៉ែមាន ១៤ ក្រុមហ៊ុន ស្មើនឹង ១៩ អាជ្ញាប័ណ្ណ និងជាលក្ខណ:សិប្បកម្មមានចំនួន ១១ អាជ្ញាប័ណ្ណ ។

❖ ក្រុមហ៊ុន Renaissance Minerals(Cambodia)Limited (ប្រទេសអូស្ត្រាលី)

ទទួលបានអាជ្ញាប័ណ្ណ និងកំពុងធ្វើអាជីវកម្មចម្រាញ់រ៉ែមាសជាផ្លូវការលើកដំបូង ចាប់ពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ រហូតដល់បច្ចុប្បន្ននេះ ចម្រាញ់រ៉ែមាសបានប្រមាណជា ៦ តោន ស្ថិតក្នុងភូមិសាស្រ្តតំបន់អូរខ្វាវ ឃុំចុងផ្លាស់ ស្រុកកែវសីមា និង

❖ ក្រុមហ៊ុន Rong Cheng Industrial Investment( Cambodia )Co.,Ltd( ចិន ) ស្ថិតក្នុងភូមិសាស្រ្តតំបន់អូរភ្លូរ ឃុំចុងផ្លាស់ ស្រុកកែវសីមា ។

❖ **អគ្គិសនី៖** បណ្តាញផ្គត់ផ្គង់អគ្គិសនីបានគ្របដណ្តប់ស្ទើរគ្រប់ភូមិនៅទូទាំងខេត្ត លើកលែង តែភូមិ មួយចំនួនតូច ដែលស្ថានភាពផ្លូវមានការលំបាកធ្វើដំណើរចូលទៅដល់ និងភូមិនៅតំបន់ ដាច់ស្រយ៉ាល នៅក្នុងព្រៃជ្រៅ ។ ជាក់ស្តែង រហូតមកដល់បច្ចុប្បន្ននេះ បណ្តាញអគ្គិសនីផ្គត់ផ្គង់ទូទាំងខេត្ត បានតភ្ជាប់បណ្តាញ MV បានប្រវែង ៦១០.២៨ គីឡូម៉ែត្រ, បណ្តាញ LV បានប្រវែង ៣៣២.១៥ គីឡូម៉ែត្រ និងផ្គត់ផ្គង់ថាមពលប្រើប្រាស់ ជូនប្រជាពលរដ្ឋប្រមាណ ១២,២៨៤ ខ្នងផ្ទះ។ អនុស្ថានីយ៍បណ្តាញចែកចាយ អគ្គិសនីពីស្ថានីយ៍សេសានពីរ បាននិងកំពុងដំណើរការសាងសង់ នៅក្នុងភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ។

❖ អង្គភាពរដ្ឋាករទឹក៖ មានលទ្ធភាពផលិតទឹកស្អាតចំនួន ២,០០០ម៣ ក្នុងមួយថ្ងៃ អាចផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋក្នុងក្រុងសែនមនោរម្យបានចំនួន ៩,០១៤នាក់ ស្មើនឹង ៥៨.៤៧%។

❖ ស្ថានីយ៍ទឹកស្អាតឯកជនមាន ៣ កន្លែង សម្រាប់ផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋប្រើប្រាស់នៅ៖
-នៅក្នុងស្រុកកោះញែក ១ កន្លែង មានលទ្ធភាពផលិតទឹកស្អាតចំនួន ១,៦៨០ ម៉ែត្រគូបក្នុងមួយថ្ងៃ ផ្គត់ផ្គង់ប្រជាពលរដ្ឋបានចំនួន ២,៦២៦ នាក់។
ឥនៅស្រុកកែវសីមា ១ កន្លែង មានលទ្ធភាពផលិតទឹកស្អាតចំនួន ១,៤៤០ម៣ ក្នុងមួយថ្ងៃ អាចផ្គត់ផ្គង់ប្រជាពលរដ្ឋបានចំនួន ២,០៥៨ នាក់
-នៅស្រុកអូររាំង ១ កន្លែង មានលទ្ធភាពផលិតទឹកស្អាតចំនួន ១,៤៤០ម៣ ក្នុងមួយថ្ងៃ អាចផ្គត់ផ្គង់ប្រជាពលរដ្ឋបានចំនួន ៥០៨ នាក់ និង
-ស្រុកពេជ្រាដា (កំពុងសាងសង់) មានលទ្ធភាពផលិតទឹកស្អាតចំនួន ១,៤៤០ម៣ ក្នុងមួយថ្ងៃ ផ្គត់ផ្គង់ប្រជាពលរដ្ឋបានចំនួន ១,៣០០ នាក់ ។

➢ **ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី៖** បានចុះបញ្ជីជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន រួមមាន ៖

❖ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ១៣ ក្រុមហ៊ុន បានចេញប័ណ្ណ ០៦ ក្រុមហ៊ុន ស្មើនឹង ៤៧ ប័ណ្ណ លើផ្ទៃដីសរុប ២៧.០៥៦ ហិកតា

❖ ស្ថានីយ៍ស្តាព្រៃឈើចំនួន ០៧ស្ថានីយ៍ បានចេញប័ណ្ណ ០២ស្ថានីយ៍ ស្មើនឹង០៤ ប័ណ្ណ លើផ្ទៃដី ៩.១០០ហិកតា

❖ ដែនជម្រកសត្វព្រៃភ្នំព្រេចចំនួន ០៤ តំបន់ បានចេញប័ណ្ណ ០៤តំបន់ ស្មើនឹង ៥៣ ប័ណ្ណ

លើផ្ទៃដី ១៧.៤៥៨១ ហិកតា និងបានទទួលពាក្យស្នើសុំចុះបញ្ជីដែនជម្រកសត្វព្រៃ ស្រែពកទំហំ ៣៧២.៩៧១ ហិកតា ។

❖ ការងារចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធបានចំនួន ៤៨ ភូមិ សម្រេចចេញប័ណ្ណបាន ចំនួន ១០ ភូមិ ស្មើនឹង ២៩៦៩ ប័ណ្ណ ស្មើនឹង ២.០៦៣ គ្រួសារ លើផ្ទៃដីទំហំ ៤,៨២៤,២៣៣ ហិកតា ការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចចំនួន ១២ សហគមន៍ និងបញ្ចប់ការបិទផ្សាយ ចំនួន ០៦ សហគមន៍ ។

➢ **វិស័យពាណិជ្ជកម្ម៖** មូលដ្ឋានអាជីវកម្មដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងខេត្ត សរុបចំនួន ១១២២ មូលដ្ឋាន រួមមាន៖ ប្រភេទពាណិជ្ជកម្មចំនួន ៩៤១ មូលដ្ឋាន ប្រភេទសេវាកម្មចំនួន ១៤៧ មូលដ្ឋាន ប្រភេទប្រេងឥន្ធនៈ និងឧស្ម័នគ្រឿងឆេះចំនួន ៣២ មូលដ្ឋាន ត្បូងថ្ម និងគ្រឿងអលង្កាមានតម្លៃចំនួន ០២ មូលដ្ឋានអាជីវកម្ម ។

➢ **វិស័យធនធានទឹក និងឧត្តុនិយម៖** ការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ក្នុងនោះបានសាងសង់

និងជួសជុលទំនប់ដីចំនួន ០៦ខ្សែ ប្រវែង សរុប ១២.០៧៥ ម៉ែត្រ ជួសជុលប្រឡាយមេចំនួន ០៩ខ្សែ ប្រវែងសរុប ១៩.២៤៩ ម៉ែត្រ ជួសជុលប្រឡាយ រងទី២ចំនួន ១០ ខ្សែ ប្រវែងសរុប ២៣.៤៥០ ម៉ែត្រ ជួសជុលប្រឡាយរងទី៣ចំនួន ៦៥ ខ្សែ ប្រវែងសរុប ៧៣.២១០ ម៉ែត្រ សាងសង់ សំណង់សិល្បៈការគ្រប់ប្រភេទបានចំនួន ៦២ កន្លែង សាងសង់ទំនប់បេតុង ០២ ខ្សែ ប្រវែងសរុប ៣៤០៨ម៉ែត្រ និងសាងសង់សំណង់ស្នាក់ទឹកខ្នាតធំ ០១កន្លែង ជប្រវែង១៣០ម៉ែត្រ

➢ **វិស័យការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ ៖** សហគ្រាសគ្រឹះស្ថានសរុបនៅក្នុងខេត្តមានចំនួន ១៩៧ សហគ្រាស ក្នុងនោះ ៖

❖ សហគ្រាសគ្រឹះស្ថានផ្នែកកសិ-ឧស្សាហកម្មចំនួន ២៣

❖ សហគ្រាសរុករករ៉ែចំនួន ០៤ ធនាគារ និង មីក្រូហិរញ្ញវត្ថុចំនួន ១៧

❖ អង្គការចំនួន ១១ និងសណ្ឋាគារ ផ្ទះសំណាក់ រីស៊ត រមណីយដ្ឋានចំនួន ១៣៥ កន្លែង

❖ ឡឥដ្ឋចំនួន ០២ និងផ្នែកសេវាកម្សាន្តចំនួន ០៥សហគ្រាស ដែលប្រើប្រាស់ កំលាំងពលកម្មសរុបចំនួន ៥,២៥៩ នាក់ ស្រី ១,៩៤៨នាក់ ។

➢ **វិស័យអប់រំ៖** សាលារៀននៅក្នុងខេត្តសរុបចំនួន ១៧១ សាលា៖

❖ សាលាមត្តេយ្យសិក្សារដ្ឋចំនួន ៣១ សាលាមត្តេយ្យសិក្សាសហគមន៍ចំនួន ២៩ កន្លែង មត្តេយ្យសិក្សាឯកជនចំនួន ៣ កន្លែង

❖ បឋមសិក្សារដ្ឋចំនួន ៨៨ សាលា បឋមសិក្សាឯកជនចំនួន ៤កន្លែង

❖ មធ្យមសិក្សាសាធារណៈចំនួន ១៤សាលា និងមធ្យមសិក្សាឯកជនចំនួន ២សាលា ដែលមានសិស្សសរុបចំនួន ២៣,២០៨ នាក់ ស្រី ១១,៩៤៩ នាក់ ក្នុងនោះ សិស្សជនជាតិដើមភាគតិច ចំនួន ៨,៤១១នាក់ ស្រី ៤,៥៤៩នាក់ ។

➢ **វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារៈ**

❖ ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ នៅក្នុងអំឡុងពេល នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ដែលបានចាប់ផ្តើមដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣នេះ ជាលទ្ធផលៈ

❖ បានចុះឈ្មោះនៅឃុំ សង្កាត់ ស្ត្រីមានផ្ទៃពោះចំនួន ១,៣០២ នាក់ និងកុមារក្រោម ២ ឆ្នាំ ចំនួន ៥៥៧ នាក់ និង

❖ ការអនុវត្តលក្ខខណ្ឌពិនិត្យ សុខភាពនៅមណ្ឌលសុខភាព ស្ត្រីមានផ្ទៃពោះចំនួន ២,៨២៣នាក់ និងកុមារក្រោម ២ ឆ្នាំ មាន ៧,៧៧៥នាក់ និងបានចំណាយថវិកាចំនួន ៧៣០,៩៦០,០០០រៀល ។

➢ **ការងារមនុស្សធម៌ៈ សាខាកាកបាទក្រហមកម្ពុជាខេត្តមណ្ឌលគិរី ៖**

❖ បានផ្តល់នូវថវិកាចំនួន ៦០,០០០,០០០៛ ផ្តល់ជូនដល់សាខាកាកបាទក្រហមកម្ពុជាខេត្តស្ទឹងត្រែង និងខេត្តក្រចេះ សម្រាប់ទិញ សម្ភារជួយដល់បងប្អូនប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់បានចំនួន ០២លើក ។

❖ បានចែកអំណោយមនុស្សធម៌ នៅក្នុងខេត្តមណ្ឌលគិរីចំនួន ៨.៩៣៧ គ្រួសារ ចំណាយថវិកាសរុប ២,៨៥៩,៨៤០,០០០៛

❖ ចែកអំណោយស្ត្រីឆ្លងទន្លេ ៣២៩ នាក់ ចំណាយថវិកាសរុប ១០៥,២៨០,០០០៛

❖ និងបានសាងសង់អណ្តូងទឹកស្អាតចំនួន ៤៣ អណ្តូង ចំណាយថវិកាសរុប ១២៤,១០០.៥៨៛

❖ សាងសង់ផ្ទះជូនប្រជាពលរដ្ឋចំនួន ៦ ខ្នង ចំណាយថវិកាសរុប ៣២,៤០០,០០០៛

❖ ជួសជុលអណ្តូងទឹកស្អាតចំនួន ៤៦ អណ្តូង ចំណាយថវិកាសរុប ៣៦,៨០០,០០០៛

➢ **វិស័យសុខាភិបាល នៅទូទាំងខេត្តមណ្ឌលគិរីៈ**

❖ ការសរុបការងារចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋនៅក្នុងខេត្តមណ្ឌលគិរី ចាប់ពីអាយុ ០៣ឆ្នាំ ឡើងៈ

- ➢ ចាក់ដូសទី១ សរុបចំនួន ១៩,៩៣០ នាក់ ស្រី ១០,២៤៧ នាក់
- ➢ ចាក់ដូសទី២ សរុបចំនួន ៥៤,៩៣១ នាក់ ស្រី ២៧,២២១ នាក់
- ➢ ចាក់ដូសទី៣ សរុបចំនួន ៦១,៧៣៧ នាក់ ស្រី ៣១,០៥៦ នាក់
- ➢ ចាក់ដូសទី៤ សរុបចំនួន ២២,១៩៥ នាក់ ស្រី ១១,៥៧១ នាក់
- ➢ ចាក់ដូសទី៥ សរុបចំនួន ៨,៩១៥ នាក់ ស្រី ៤,៣៥៥ នាក់

➢ ចាក់ជូសទី៦ សរុបចំនួន ១,២៧៣ នាក់ ស្រី ៣៧៣ នាក់

## II.អំពីហេដ្ឋារចនាសម្ព័ន្ធ និងការកែលម្អសោភ័ណ្ឌភាពខេត្ត៖

-ការអនុវត្តគម្រោងគុណប្រយោជន៍ខេត្ត ក្នុងនោះមានការសាងសង់សំណង់ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗជាច្រើនដូចជា ផ្លូវក្លោះ ផ្លូវទំនប់លើក្រោម ផ្លូវវាងក្រុង និងផ្លូវខេត្តជាច្រើនទៀត រួមទាំង ការសាងសង់ និងដាក់លូ មានលូមូល លូជ្រុង លូប្រអប់ ផ្លូវបេតុង ផ្លូវចាក់កៅស៊ូ បណ្តាញអគ្គិសនី ផ្សារថ្មីក្រុងសែនមនោរម្យ ចំណតរថយន្ត អគាររដ្ឋបាលសាលាខេត្ត សាលប្រជុំសាលាខេត្ត អគារធ្វើ ការងារផ្សេងៗនៅក្នុងសាលាខេត្ត សួនច្បារសាធារណៈ សួនច្បារក្នុងសាលាខេត្ត និងផ្លូវបេតុងជុំវិញបឹងទំនប់សែនសុខដុម ផ្លូវជុំវិញបឹងទំនប់សែនមនោរម្យ វិមានឯករាជ្យខេត្ត រូបសំណាកសេះ នាគ ឃ្លោក រង្វង់មូលដំរី រូបសំណាកដំរី "សូមស្វាគមន៍ក្រុងសែនមនោរម្យ" ស្លាក អរគុណសន្តិភាព និងការរៀបចំបង្គោល ភ្លើងបំភ្លឺតាមទីសាធារណៈនៅក្នុងក្រុង ដែលសរុបចំនួន ១២០គម្រោង ដែលមានទឹកប្រាក់សរុបចំនួន ១៦,៣៧៩,៦០៨,៣២២,០០០ រៀល (ដប់ប្រាំកណ្តកសញ្ញា បីរយចិតសិប ប្រាំបួនបីលាន ប្រាំមួយរយ ប្រាំបីលាន បីរយម្ភៃពីរពាន់រៀល)។

➢ **វិស័យសាធារណៈការ និងដឹកជញ្ជូន៖**

-ការងារថែទាំប្រចាំផ្លូវជាតិ និងផ្លូវខេត្តៈ ចំនួន ០៥ខ្សែ ក្រាលកៅស៊ូប្រវែងសរុប ២៤៨.៦៦ គីឡូម៉ែត្រ

-ការងារថែទាំខួប កាត់ជួសជុលផ្លូវជាតិលេខ៧៦ បានប្រវែង ១៧.៨១គីឡូម៉ែត្រ

-កាត់ជួសជុលផ្លូវខេត្តលេខ៣៧៦០ បានប្រវែង ២៣គីឡូម៉ែត្រ

-កាត់ជួសជុលផ្លូវខេត្តលេខ៣៧៦៣ បានប្រវែង ២៣គីឡូម៉ែត្រ

-កាត់ជួសជុលផ្លូវខេត្តលេខ៣៧៦៤ បានប្រវែង ១១.១៥គីឡូម៉ែត្រ

-ស្តាបនាផ្លូវខេត្តលេខ៣៧៦៤ បានប្រវែង ២៣គីឡូម៉ែត្រ

-កាត់ជួសជុលផ្លូខេត្តលេខ៣៧៦០D បានប្រវែង ៩៥០ម៉ែត្រ និងសំណង់សិល្បការ

-ស្តាបនាស្ពានបេតុងបានប្រវែង ១៨ ម៉ែត្រ ទទឹង ៨ ម៉ែត្រ លើកំណាត់ផ្លូវខេត្តលេខ៣៧៦៤

-ស្តាបនាស្ពានបេតុង បានប្រវែង ៤៥ ម៉ែត្រ ទទឹង ១០ ម៉ែត្រ លើកំណាត់ផ្លូវខេត្តលេខ ៣៧៦៤

-ស្តាបនាស្ពានបេតុងសសៃដែក ប្រវែង ២៤ម៉ែត្រ ទទឹង ១០ម៉ែត្រ លើកំណាត់ផ្លូវខេត្តលេខ ៣៧៦៤

-ស្តាបនាស្ពានដាឡូ ប្រវែង ១០ម៉ែត្រ ទទឹង ១០ម៉ែត្រ លើកំណាត់ផ្លូវខេត្ត៣៧៦៤ សាងសង់លូបេតុង ø១០០ ចំនួន ៩០ម៉ែត្រ សាងសង់លូប្រអប់ បានចំនួន ៨០ម៉ែត្រ ។

➢ **វិស័យជនបទ៖** ការងារសាងសង់ និងជួសជុលផ្លូវលំជនបទនៅក្នុងខេត្ត ៖

-ជួសជុល ថែទាំផ្លូវជនបទលក្ខណៈប្រចាំ (ប្រភេទល្បាយថ្មភ្នំ ទទឹងខ្នងលើ ៦ម៉ែត្រ) ចំនួន ២៥ខ្សែ ប្រវែងសរុប ៣៥៤,២០០ម៉ែត្រ

-ការងារថែទាំផ្លូវជនបទលក្ខណៈខួប (ប្រភេទល្បាយថ្មភ្នំ ទទឹងខ្នងលើ ៦ម៉ែត្រ) ចំនួន ០៧ខ្សែ ប្រវែងសរុប ៦៥,០០០ម៉ែត្រ

-ជួសជុលថែទាំផ្លូវជនបទលក្ខណៈសង្គ្រោះបន្ទាន់ (ប្រភេទល្បាយថ្មភ្នំ ទទឹងខ្នងលើ ៦ម៉ែត្រ) ចំនួន ៨ខ្សែ ប្រវែងសរុប ២០,៣០០ម៉ែត្រ

-ជួសជុលផ្លូវជនបទក្រាលល្បាយថ្មភ្នំ ១ខ្សែ ប្រវែង ៥៦,០០០ម៉ែត្រ ជួសជុល ពង្រីកផ្លូវថ្មីចំនួន ១១ខ្សែ ប្រវែងសរុប ៤៤,០០០ម៉ែត្រ

-សាងសង់លូមូលសរុប ២៥កន្លែង សាងសង់ស្ពានបេតុងចំនួន ០៣កន្លែង ប្រវែងសរុប ១១២ម៉ែត្រ និងសាងសង់ស្ពានឈើ (ទទឹង៤ម)ចំនួន ០៤កន្លែង ។

-ជួសជុលអណ្តូងស្នប់អេហ្វ្រីដេវសរុប ៤៦អណ្តូង សាងសង់អណ្តូងស្នប់អេហ្វ្រីដេវសរុប ៣១អណ្តូង សាងសង់អាងត្រងទឹកភ្លៀងចំនួនចំណុះ ៤ ម៉ែត្រគ្រីគុណ សរុប ៨៦អាង

## III. **អំពីផែនការអភិវឌ្ឍន៍ខេត្តមណ្ឌលគិរី**

ខេត្តមណ្ឌលគិរី ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា កំណត់ជាខេត្តប៉ូលសេដ្ឋកិច្ចទី៤ បន្ទាប់ពីរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប ។ តាមរយៈការកំណត់នេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងទេសចរណ៍ បានដាក់ចេញនូវផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ ខេត្តមណ្ឌលគិរី ឆ្នាំ២០២១-២០៣៥ ដែលជាផែនការយុទ្ធសាស្ត្រមួយក្នុងជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ឱ្យមានការរីកចម្រើន និងមានកំណើន សេដ្ឋកិច្ច បង្កើនការងារជូនប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលក្នុងខេត្ត ។

អនុវត្តន៍បានយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដើម្បីជានាពង្រឹងនូវការគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងខេត្ត ធ្វើឱ្យសភាពការណ៍ សន្តិសុខ និងសណ្តាប់ធ្នាប់ នៅក្នុងខេត្តមានភាពល្អប្រសើរ ។ នៅគ្រប់កាលៈទេសៈ កងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ផ្នែក មានលទ្ធភាព គ្រប់គ្រាន់ក្នុងការចូលរួម និងថែរក្សាការពារបាននូវ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ព្រមទាំង កិច្ចអន្តរាគមន៍ជួយសង្គ្រោះប្រជាពលរដ្ឋបានទាន់ពេលវេលានៅក្នុងស្ថានភាពដែលមានគ្រោះមហន្តរាយកើតមានឡើង ។ ទន្ទឹមនឹងនោះដែរ ស្ថានភាពសន្តិសុខសណ្តាប់ធ្នាប់នៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែន កម្ពុជា-វៀតណាម មានស្ថានភាពល្អប្រសើរ ទោះបីជាមានបញ្ហាខ្លះៗកើតមានឡើង ដោយឈរលើស្មារតីកិច្ចសហប្រតិបត្តិការល្អ ការរក្សាបាននូវសន្តិភាព សាមគ្គីភាព មិត្តភាព និងការពារអធិបតេយ្យភាព បូរណភាពទឹកដី និងការអភិវឌ្ឍន៍នៅតាមតំបន់ព្រំដែន ។

បន្តពង្រឹងយ៉ាងខ្ជាប់ខ្ជួនក្នុងការអនុវត្តន៍គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការទប់ស្កាត់ និង បង្ក្រាបបទល្មើសធនធានធម្មជាតិ បទល្មើសព្រៃឈើ បទល្មើសគ្រឿងញៀន បទល្មើស

ការកាប់រានទន្រ្ទានព្រៃ យកដីធ្វើកម្មសិទ្ធិខុសច្បាប់ បទល្មើសជួញដូរមនុស្ស និងបទល្មើសឆ្លងដែនខុសច្បាប់ផ្សេងៗជាច្រើនទៀត ។

សរុបជារួមមក នៅក្នុងខេត្តមណ្ឌលគិរី ក្រោមការដឹកនាំរបស់រដ្ឋបាលខេត្តមណ្ឌលគិរី ដែលមានក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត រួមនឹងការគាំទ្រជាចាំបាច់របស់ក្រុម ការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តមណ្ឌលគិរី ដែលដឹកនាំដោយ ឯកឧត្តម **ខី ចន្ទ្រផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានធ្វើឲ្យខេត្តមណ្ឌលគិរី មានការអភិវឌ្ឍរីកចម្រើនឡើង លើគ្រប់វិស័យ។ ក្នុងនោះ ការងារគ្រប់គ្រងរដ្ឋបាល ការរក្សាសន្តិ-សុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការងារកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ចល្អ ការងារផ្តល់សេវាសាធារណៈ សេវារដ្ឋបាល ការងារគ្រប់គ្រងព្រំដែន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការអភិវឌ្ឍសមត្ថភាព ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ការអភិវឌ្ឍវិស័យឯកជន វិស័យការងារ និងវិស័យបណ្តុះបណ្តាល ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងគ្រោះមហន្តរាយ ការគ្រប់គ្រងដីសាធារណៈរបស់រដ្ឋ ការដោះស្រាយទំនាស់ដីធ្លី ក៏កំពុងត្រូវបានជានា និងមានការអភិវឌ្ឍរីកចម្រើនគួរឲ្យកត់សម្គាល់ ធ្វើឱ្យខេត្តទាំងមូលមានការប្រែមុខមាត់ថ្មី ព្រមទាំងបានលើកកម្ពស់ស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពប្រសើរឡើង ពីមួយឆ្នាំទៅមួយឆ្នាំ ។

ទន្ទឹមនឹងនេះដែរ ចំពោះរដ្ឋបាលខេត្ត ក៏បានទទួលនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ពីក្រសួងមហាផ្ទៃ ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់គ្រប់គ្រង និងចាត់ចែងអនុវត្តកិច្ចការនៅមូលដ្ឋាន ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការដាក់ស្តែងរបស់ប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឲ្យមានការអភិវឌ្ឍ រីកចំរើន គួរឲ្យកត់សម្គាល់។ ក្នុងនាមរដ្ឋបាលខេត្ត ខ្ញុំសូមប្តេជ្ញាថា នឹងខិតខំបន្តអនុវត្តនូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ និងដំណាក់កាលបន្តបន្ទាប់ទៀត ដែលបានរួមចំណែកដ៏ធំធេងក្នុងការរក្សាបាននូវសន្តិសុខស្ថេរភាពនយោបាយ សង្គម និងបង្កើនគុណភាព នៃការផ្តល់សេវាប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព មានការអភិវឌ្ឍប្រកបដោយចីរភាព បង្កើតបាននូវបុរេល័ក្ខខ័ណ្ឌចាំបាច់ និងបរិស្ថានអនុគ្រោះ សម្រាប់ការប្រែក្លាយខ្លួនឲ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ៕

## IV-ទិសដៅអនុវត្តបន្ត

- កសាង និងកែលម្អ ព្រមទាំងថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ទាំងនៅទីក្រុង និងជនបទ ដើម្បី លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។
- កសាង និងកែលម្អប្រព័ន្ធស្រោចស្រព ដើម្បីឆ្លើយតបតម្រូវការដាំដុះដំណាំកសិកម្មរបស់បងប្អូនប្រជាពលរដ្ឋនៅជនបទសំដៅបង្កើនប្រាក់ចំណូលដែលធ្វើឲ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ។

- ពង្រឹងសមត្ថភាព និង កែលម្អរចនាសម្ព័ន្ធសុខាភិបាលឲ្យបានល្អប្រសើរឡើងនូវការផ្តល់សេវា សុខភាព ជូនប្រជាពលរដ្ឋ ជាពិសេសសុខភាពមាតា ទារក និងកុមារ ។
- ពង្រឹងការគ្រប់គ្រង និងបង្កើនគុណភាព បរិមាណ នៃផលិតផលកសិកម្ម សិប្បកម្ម អាជីវកម្ម ពាណិជ្ជកម្ម ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសជនពិការ ឲ្យមានភាព ប្រសើរឡើង ។
- កែលម្អ ពង្រីក និងថែរក្សារមណីយដ្ឋានទេសចរណ៍រួមទាំងអេកូទេសចរណ៍ ទន្ទឹមនឹងនោះ ពង្រឹង គុណភាព សេវាទេសចរណ៍ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ។
- កសាង និងពង្រីកបណ្តាញអគ្គិសនីនៅក្នុងទីក្រុង ទីប្រជុំជន និងជនបទ ដើម្បីជំរុញការវិនិយោគ លើវិស័យកសិ-ឧស្សាហកម្ម សិប្បកម្ម និងអាជីវកម្ម ។
- កសាង ពង្រឹង និងពង្រីកប្រព័ន្ធបណ្តាញទឹកស្អាតនៅក្នុងក្រុង ទីប្រជុំជន និងផ្គត់ផ្គង់ទឹកស្អាត នៅតាមជនបទ ។
- កសាងហេដ្ឋារចនាសម្ព័ន្ធ និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់នៅក្នុងទីប្រជុំជនក្រុង ។
- កែលម្អបរិស្ថានសាលារៀន ការកសាងអគារសិក្សា ដើម្បីលើកកម្ពស់សេវាអប់រំប្រកបទៅដោយ គុណភាព និងប្រសិទ្ធភាពនៅគ្រប់សាលាទូទាំងខេត្ត (មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ សាលាគរុកោសល្យ) ។
- កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដើម្បីលើកកម្ពស់គុណភាព នៃការផ្តល់សេវាថែទាំ និងព្យាបាល សុខភាពរបស់ប្រជាពលរដ្ឋ ។
- ពង្រឹង និងកែលម្អការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ជាពិសេសបង្កើនការការពារ និងដាំដើមឈើ ដើម្បីធានាបាននូវចីរភាពធនធានធម្មជាតិជាអតិបរមា ។
- បង្កើន និងពង្រឹងការគ្រប់គ្រងប្រើប្រាស់ដីធ្លីដោយជំរុញការចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិជូនដល់ ប្រជាពលរដ្ឋ ដែលធានាបាននូវការប្រើប្រាស់ដីរដ្ឋ និងឯកជនស្របច្បាប់ ដែលឈានទៅកាត់បន្ថយជម្លោះដីធ្លីបានជាអតិបរមាព្រមទាំងបង្កើនចំណូលសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ ។
- បង្កើនការអប់រំផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនានា ដើម្បីរៀបចំអនុវត្តផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលឈានទៅកាត់បន្ថយនូវផលប៉ះពាល់ជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព ។

- ពង្រឹងការគ្រប់គ្រងរដ្ឋបាល និងបង្កើននូវការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ធានាបាននូវកិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង ។
- ការពង្រឹង និងបង្កើនការយកចិត្តទុកដាក់លើការផ្តល់សេវាសាធារណៈ តាមច្រកចេញ-ចូលតែមួយជូនប្រជាពលរដ្ឋទូទៅឲ្យកាន់តែមានភាពល្អប្រសើរឡើង ។
- កែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ការផ្តល់សេវាជូនដល់ប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង ។
- បង្កើន និងលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដែលជានាទូវការលើកកម្ពស់ការ ផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងតម្លាភាព
- លើកកម្ពស់ និងពង្រឹងការថែរក្សាវប្បធម៌ ប្រពៃណីយទំនៀមទំលាប់ខ្មែរឲ្យបានល្អប្រសើរ
- ពង្រឹងរបៀបរបបការងារ និងការអនុវត្តតួនាទីភារកិច្ចបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការ ផ្តល់សេវាជូនប្រជាពលរដ្ឋ ឲ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។
- បន្តពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានា និង ធានាថា មន្ត្រីពាក់ព័ន្ធមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។
- បន្តលើកកម្ពស់ យន្តការគណនេយ្យភាពតាមរយៈប្រអប់សំបុត្រគណនេយ្យភាព និងការរៀបចំវេទិកាផ្សព្វផ្សាយពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដើម្បីក្តាប់បាននូវសំណូមពរ និងបញ្ហានានា នៅមូលដ្ឋាន និងដាក់ចេញនូវវិធានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ។
- បន្តផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ធានាបាននូវការអនុវត្តកិច្ចការ របស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។
- ចូលរួមយ៉ាងសកម្ម ក្នុងការសហការអនុវត្តនូវផែនមេអភិវឌ្ឍន៍ វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ឱ្យបានសមស្របទៅនឹងការដាក់ចេញនូវផែនការអភិវឌ្ឍន៍ខេត្តមណ្ឌលគិរី និងការកំណត់របស់ រាជរដ្ឋាភិបាល "មណ្ឌលគិរី ជាខេត្តប៉ូលសេដ្ឋកិច្ចទី៤" ។

**ជាទីបញ្ចប់** ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរចំពោះ សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ សូមថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម **សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំង សម្តេចព្រះមហាក្សត្រី នរោត្តម **មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គទាំងទ្វេ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់

ជាម្លប់ដ៏ដ៏ត្រជាក់ត្រជុំដល់ប្រជារាស្ត្ររបស់ព្រះអង្គ និងសូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និសីទទាំងមូល សូមបានសមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ** !